**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខៈ ១០៥ .......សហវ.ប្រក.

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០០៨

# ប្រកាស

## ស្តីពី

## ការគ្រប់គ្រងទំនិញគ្មានការទាមទារ

## ទេសរដ្ឋមន្ត្រី

## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខនស/រកម/០៧០៧/០១៧ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ២០០៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីគយ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- យោងតាមសំណូមពរការងារចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

**<u>សម្រេច</u>**

**ប្រការ ១.-**

ត្រូវបានដាក់ឱ្យស្ថិតក្រោមការគ្រប់គ្រង និងត្រួតពិនិត្យរបស់គយស្រប តាមបញ្ញត្តិមាត្រា ៤៨ នៃច្បាប់ស្តីពីគយនូវទំនិញ គ្មានការទាមទារ ដូចជាៈ

ទំនិញរក្សាទុកក្នុងទីកន្លែងសន្និធិគយបណ្តោះអាសន្ន ឬនៅក្នុង ភណ្ឌាគារគយមានដែនកំណត់ដែលហួសរយៈពេលកំណត់នៃការធ្វើប្រកាស

ស្តីពីសន្និធិគយបណ្តោះអាសន្ន ឬប្រកាសស្តីពីកណ្តាគារគយមានដែនកំណត់ ។

- ទំនិញដែលពុំត្រូវបានធ្វើប្រតិវេទន៍គយក្នុងរយៈពេលកំណត់ក្រោមបញ្ញត្តិនៃប្រកាសស្តីពីសន្និធិគយបណ្តោះអាសន្ន ។

- ទំនិញផ្ញើតាមប្រៃសណីយ៍ដែលគម្យជនបដិសេធមិនទទួលយក ឬគម្យជនពុំត្រូវបានរកឃើញ និងមិនអាចបញ្ជូនទំនិញត្រឡប់ទៅអ្នកផ្ញើវិញបាន ។

- ទំនិញ និងមធ្យោបាយដឹកជញ្ជូនពុំជាប់អយ័ត ដែលស្ថិតនៅក្នុងកន្លែងបញ្ចេញទំនិញពីគយ ហើយម្ចាស់បានបោះបង់ចោលជាលាយល័ក្ខណ៍អក្សរ ។

**ប្រការ ២.-**

ទំនិញគ្មានការទាមទារដែលស្ថិតក្រោមការគ្រប់គ្រង និងត្រួតពិនិត្យរបស់គយ ត្រូវចុះក្នុងបញ្ជីនៃនិក្ខិត្តភ័ណ្ឌគយដោយឡែកមួយ ។ ទំនិញគ្មានការទាមទារដែលមានតម្លៃតិចជាង ពីររយពាន់ ( ២០០.០០០ ) រៀល អាចត្រូវបានចាត់ចែងតាមគម្យដ្ឋានណាមួយដោយ រដ្ឋបាលគយ ។

**ប្រការ ៣.-**

ប្រសិនបើម្ចាស់ទំនិញត្រូវបានស្គាល់ រដ្ឋបាលគយត្រូវជូនដំណឹងជាបន្ទាន់ ដល់ម្ចាស់ទំនិញគ្មានការទាមទារថា ទំនិញទាំងនោះនឹងត្រូវដាក់លក់ដោយដេញថ្លៃជាសាធារណៈស្របតាមបញ្ញត្តិនៃប្រកាសនេះ កាលណាពុំមានការទាមទារក្នុងរយៈពេល ហុកសិប (៦០) ថ្ងៃ គិតពីថ្ងៃចេញសេចក្តីជូនដំណឹងនេះ ។

**ប្រការ ៤.-**

ក្នុងករណីពុំអាចរកម្ចាស់ឃើញ ឬពុំស្គាល់ម្ចាស់រដ្ឋបាលគយត្រូវចេញប្រវេសន៍សាធារណៈ ហើយបិទផ្សាយនៅការិយាល័យគយ ឬសាលាឃុំ - សង្កាត់ជិតបំផុតដើម្បីជាការជូនដំណឹងដល់ម្ចាស់ទំនិញ ។ ប្រវេសន៍នេះត្រូវមានចែងពី ៖

- បរិយាយមុខទំនិញ និងទីកន្លែងនៃទំនិញ

- កាលបរិច្ឆេទដែលទំនិញត្រូវបានចុះក្នុងបញ្ជីនិក្ខិត្តភ័ណ្ឌគយ

- កាលបរិច្ឆេទដែលទំនិញអាចត្រូវបានចាត់ចែងតាមគម្យដ្ឋាន បន្ទាប់ពីការដាក់លក់ដោយដេញថ្លៃជាសាធារណៈ ឬក្រោយរយៈពេល ហុកសិបថ្ងៃ (៦០) គិតពីថ្ងៃចេញប្រវេសន៍សាធារណៈ

- ការិយាល័យគយដែលទទួលខុសត្រូវគ្រប់គ្រង និងត្រួតពិនិត្យទំនិញ ដោយបញ្ជាក់នូវអាស័យដ្ឋានទំនាក់ទំនងលម្អិត ។

**ប្រការ ៥.-**

ការចំណាយនានាដែលកើតមានក្នុងពេលដែលទំនិញគ្មានការទាមទារស្ថិតក្រោមការគ្រប់គ្រង និងត្រួតពិនិត្យរបស់គយជាបន្ទុករបស់ម្ចាស់ទំនិញ ។

**ប្រការ ៦.-**

មន្ត្រីគយអាចបើក ឬត្រួតពិនិត្យទំនិញគ្មានការទាមទារស្ថិតក្រោមការគ្រប់គ្រង និងត្រួតពិនិត្យរបស់គយ តែពេលមានវត្តមានរបស់ម្ចាស់ទំនិញ ។ ក្នុងករណីដែលម្ចាស់ទំនិញអវត្តមាន ការត្រួតពិនិត្យនេះត្រូវមានវត្តមានរបស់បុគ្គលដែលត្រូវបានចាត់តាំងដោយតុលាការមានសមត្ថកិច្ចតាមសំណើរបស់រដ្ឋបាលគយ។

**ប្រការ ៧.-**

ក្រោយរយៈពេល ហុកសិបថ្ងៃ (៦០) គិតពីថ្ងៃចេញប្រវេសន៍សាធារណៈខាងលើ ម្ចាស់ទំនិញត្រូវធ្វើការទាមទារទំនិញរបស់ខ្លួន ។ ប្រសិនបើហួសរយៈពេលនេះ ទំនិញនឹងត្រូវដាក់លក់ដោយដេញថ្លៃជាសាធារណៈ ស្របតាមបញ្ញត្តិនៃប្រកាសនេះ ។

រដ្ឋបាលគយត្រូវទទួលខុសត្រូវរៀបចំចាត់ចែងការដាក់លក់ដោយដេញថ្លៃជាសាធារណៈនូវទំនិញគ្មានការទាមទារ ស្របតាមនីតិវិធីជាធរមានដល់អ្នកដេញថ្លៃដែលហ៊ានឱ្យថ្លៃខ្ពស់បំផុត ។ ទំនិញគ្មានការទាមទារដែលបានដាក់លក់ពុំត្រូវជាប់បន្ទុកពន្ធ និងអាករនាំចូលឡើយ ។ អ្នកដេញថ្លៃបានមានសិទ្ធិប្រើប្រាស់ទំនិញទាំងនេះស្របតាមបញ្ញត្តិនៃច្បាប់ និងបទប្បញ្ញត្តិជាធរមាន ។

ទំនិញប្រកបដោយគ្រោះថ្នាក់ ឬងាយខូចខាត ឬពុំអាចរក្សាទុកបាន អាចត្រូវបានលក់ជាបន្ទាន់ដោយមានការអនុញ្ញាតពីនាយកទីចាត់ការគយ និងរដ្ឋាករ ។

ទំនិញមានតម្លៃតិចជាង ពីរលាន (២.០០០.០០០) រៀល ដែលមិនត្រូវបានយកចេញពីគយក្នុងរយៈពេល ហុកសិប ( ៦០ ) ថ្ងៃ ដូចមានចែងក្នុងកថាខណ្ឌទីមួយនៃមាត្រានេះ អាចត្រូវ បានធ្វើជាអំណោយដោយរដ្ឋបាលគយដល់មន្ទីរពេទ្យ អង្គការសង្គម កិច្ច អង្គការមនុស្សធម៌ ឬស្ថាប័នរដ្ឋដទៃទៀត ។

**ប្រការ ៨.-**

ផលពីការលក់ដោយដេញថ្លៃជាសាធារណៈត្រូវទូទាត់សងប្រាក់ពន្ធ និងអាករដែលមិនទាន់បានបង់ កម្រៃ និងបន្ទុកផ្សេងៗ និងចំណាយរៀបចំការដាក់លក់ដោយតាមលំដាប់អាទិភាពដូចតទៅ ៖

- សងថ្លៃចំណាយរៀបចំការដាក់លក់ដោយដេញថ្លៃ និងចំណាយផ្សេងៗ ដែលកើតមានក្នុងពេលដែលទំនិញគ្មានការទាមទារស្ថិតក្រោមការគ្រប់គ្រង និងត្រួតពិនិត្យរបស់គយ

- ការបង់ពន្ធ និងអាករដែលមិនទាន់បានបង់

- សងថ្លៃចំណាយផ្សេងទៀតពាក់ព័ន្ធនឹងទំនិញគ្មានការទាមទារ ។

ទឹកប្រាក់ដែលនៅសល់ពីការទូទាត់ខាងលើ ត្រូវផ្ទេរចូលគណនីប្រាក់បញ្ញើរបស់រដ្ឋបាលគយ និងរក្សាទុកនៅទីនោះសម្រាប់រយៈពេល ប្រាំមួយ (៦)ខែ ។ ម្ចាស់ទំនិញអាចទាមទារយកនូវទឹកប្រាក់នៅសល់ក្រោយពីការទូទាត់នេះបាន ក្នុងរយៈពេល ប្រាំមួយ (៦) ខែ តាមសេចក្ដីជូនដំណឹងរបស់រដ្ឋបាលគយដែលត្រូវធ្វើឡើងក្នុងរវាងប្រាំពីរ (៧) ថ្ងៃបន្ទាប់ពីការលក់ដោយដេញថ្លៃ ។

ហួសរយៈពេលកំណត់នេះ ប្រសិនជាមិនមានការទាមទារយកទឹកប្រាក់នេះទេ ទឹកប្រាក់នេះនឹងត្រូវបង់ចូលថវិការដ្ឋ ។ ក្នុងករណីដែលទឹកប្រាក់នៅសល់ពីការទូទាត់មិនលើសពី ពីរលាន(២.០០០.០០០)រៀល ត្រូវបង់ចូលថវិការដ្ឋជាបន្ទាន់។

**ប្រការ ៩.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ១០.-**

ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជានាយកទីចាត់ការគយ និងរដ្ឋាករ អគ្គលេខាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋាន និងអង្គភាពនានាក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ព្រមទាំងបុគ្គល និងស្ថាប័នពាក់ព័ន្ធផ្សេងទៀត ត្រូវអនុវត្តតាមខ្លឹមសារប្រកាសនេះឲ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។/.

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**គាត ឈន់**

**ចម្លងជូន ៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតី តេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីជូនជ្រាប"
- ទីចាត់ការគយ និងរដ្ឋាករ
- ដូចប្រការ ១០
- សភាពាណិជ្ជកម្មកម្ពុជា "ដើម្បីសហការផ្សព្វផ្សាយ និងអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ